**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៤៥៧
ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣
**សាលដីកា**
លេខៈ១៦៥
ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៥ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម .............. ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ................ ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក ............... ជាចៅក្រមរបាយការណ៍
៥-លោក ............... ជាចៅក្រម
៦-លោក ................ ជាចៅក្រម
៧-លោក ................... ជាចៅក្រម
៨-លោក ................. ជាចៅក្រម
៩-លោក .................. ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក ....................

**តំណាងមហាអយ្យការ**

-ឯកឧត្តម ................. ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ពីសាលដីការដ្ឋប្បវេណីលេខ៩៧(ច) ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៨២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍រវាងៈ

ដើមចោទឈ្មោះហផល (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រីអាយុ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិពោធិចិន្តាំ ឃុំស្វាយអន្តរ ស្រុក-ខេត្តព្រៃវែង ។ ឪពុកឈ្មោះដេត ហ៊ុត(រ) ម្តាយឈ្មោះជុន យឿន(រ) ប្តីឈ្មោះហ៊ី នៅ មានកូន០៣នាក់ ។

ចុងចម្លើយឈ្មោះឈថ (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៤៨ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីធ្វើស្រែ ទីលំនៅភូមិពោធិចិន្តាំ ឃុំស្វាយអន្ទរ ស្រុក-ខេត្តព្រៃវែង ។ ឪពុកឈ្មោះព្រឿង ឈាង(ស)ម្តាយឈ្មោះរ៉ា យ៉េង(រ) ប្រពន្ធឈ្មោះទឹម អូន មានកូន០៧នាក់ ។

មានមេធាវីលោក ............ ។

**<u>កម្មវត្ថុបណ្តឹង:</u>** ប្តឹងទាមទារដីបុងទឹក

បានឃើញបណ្តឹងសាទុក្ខលើកទី២លខ៣១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះហផល ប្តឹងមិនសុខចិត្ត និងសាលដីការដ្ឋប្បវេណីលេខ៩៧(ច) ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៤៥៧ ចុះថ្ងៃទី០១ខែធ្នូ ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១១-០៦-២០០១ របស់ដើមចោទថា: ខ្លួនប្តឹងទាមទារដីបុងទឹក នេះពីចុងចម្លើយឈ្មោះឈថ ប្រពន្ធឈ្មោះទឹម អួន ដោយអាងហេតុថា : ដំបូងទឹកនេះ ខ្លួនកាន់កាប់តាំងពីឆ្នាំ១៩៧៩ មករហូតដល់ឆ្នាំ២០០១ នេះ ឈថ ប្តឹងទៅសាលស្រុកព្រៃវែង ថាខ្លួនរំលោភបំពានលើដីរបស់គេទៅវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៣៤ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១ របស់តុលាការខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១១-០៦-២០០១ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ប្រគល់ដីបុងទឹកទំនាស់ដែលមានផ្ទៃក្រឡាចំនួន៣៥៤ម$^{២}$ មានព្រំប្រទល់ខាង ជើងទល់ដីដើមចោទ ខាងត្បូងទល់ផ្លូវដើរ ខាងលិចទល់ដីចុងចម្លើយ និងខាងកើតទល់ផ្លូវជាតិលេខ១១ ដោយចេញមិនរំលោភដីសាធារណៈ ទល់ដីសាធារណៈ ។ ដីបុងទឹកទំនាស់នេះ ស្ថិតនៅក្នុងភូមិពោធិចិន្តាំ ឃុំស្វាយអន្ទរ ស្រុកព្រៃវែងខេត្តព្រៃវែង ឱ្យទៅឈ្មោះហផល ជាដើមចោទគ្រប់គ្រងធ្វើជាកម្មសិទ្ធិចាប់ពីថ្ងៃនេះតទៅ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី៧.០០០៛ ប្រាក់នេះដើមចោទបានបង់រួចហើយ ក្នុងនោះដាក់ចូលពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង សរុប១៨០០៛ រង្វាន់ត្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥.០០០៛ កាលបើផុតបណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយសងប្រាក់៧.០០០៛ នេះទៅដើមចោទវិញ និងឱ្យចុងចម្លើយបង់ពន្ធសមាមាត្រមួយភាគរយនៅលើតម្លៃដីបុងនេះបន្ថែមទៀត។ តម្លៃដីបុងស្មើ២.០០០ដុល្លារអាមេរិក(ពីរពាន់ដុល្លារអាមេរិក) គុណ ១ ចែក ១០០ស៊ី ២០ដុល្លារអាមេរិក ប្រាក់ពន្ធនេះដាក់ចូលថវិការដ្ឋ៨០%រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។ប្រាក់ពន្ធនេះ ឱ្យដើមចោទបង់ជាមុនសិន ទើបបង្គាប់ឱ្យចុងចម្លើយសងទៅដើមចោទវិញជាក្រោយ ។

-សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើភាគីណាមិនសុខចិត្ត នឹងសេចក្តីសម្រេចនេះ បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល២ខែ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៥៨ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១ របស់ឈ្មោះឈថ ប្តឹងមិនសុខចិត្ត នឹងសាលក្រមរដ្ឋប្បវេណីលេខ១៣៤ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១ របស់តុលាការខេត្តព្រៃវែង ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២៧(ង) ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៨-១០-២០០១ របស់ដើមបណ្តឹងឧទ្ធរណ៍ ឈ្មោះឈថ និងទឹម អូន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ១៣៤ ចុះថ្ងៃទី០៨-១០-២០០១ របស់តុលាការ ខេត្តព្រៃវែង ចោលជាអសារបង់ ។

៣-ប្រគល់ដីទំនាស់ទំហំ៣៥៤ម² ដែលមានព្រំប្រទល់ខាងជើងទល់នឹងឈ្មោះយឿន មុំ ខាងត្បូងទល់និងផ្លូវ ខាងកើតទល់នឹងផ្លូវជាតិលេខ១១ និងខាងលិចទល់នឹងឈ្មោះថុន អូន តាមគំនូសប្លង់ចុះថ្ងៃទី៣០-០៧-២០០១ របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលស្រុកព្រៃវែងទៅឱ្យឈ្មោះឈថ និងប្រពន្ធឈ្មោះទឹម អូន កាន់កាប់ជាកម្មសិទ្ធិនៅ ពេលដែលសាលក្រមនេះចូលជាស្ថាពរ ។

៤-កាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺ : ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន៥.០០០៛ និងអាជ្ញាធរតុលាការចំនួន៥.០០០៛ សរុប១៣.០០០៛ ។ កាលបើផុតកំណត់ប្តឹងសាទុក្ខបង្គាប់ឲ្យដើមចោទសងប្រាក់១៣០០០៛ នេះទៅឲ្យចុងចម្លើយវិញ និងបង្គាប់ឲ្យដើមចោទបង់ពន្ធសមាមាត្រ១% លើតម្លៃដីទំនាស់ ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៦ ចុះថ្ងៃទី១២ ខែកុម្ភៈឆ្នាំ២០០២ របស់ឈ្មោះហាផល ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២៧(ង) ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២០៤ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០២ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលបណ្តឹងសាទុក្ខលេខ៥៦ ចុះថ្ងៃទី១២-០២-០២ របស់អ្នកស្រីហាផល ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ២៧(ង) ចុះថ្ងៃទី១១-០២-០២ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៥៦ ចុះថ្ងៃទី១៨-០៣-០២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩០០០៛ ដែអ្នកស្រីហផល បានបង់រួចហើគឺ៖

-ពន្ធចុះបញ្ជីក្តីនឹងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីការកោះចំនួន១៥០០០៛ សរុប១៩០០០៛ ហើយតម្រូវឲ្យលោកឈថ សងប្រាក់ចំនួន១៩០០០៛ នេះទៅអ្នកស្រីហផល វិញ ។

៥-សាលដីការនេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៦ខែសីហា ឆ្នាំ២០០២ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩៧(ច)ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ បានសម្រេចសេចក្តីជាថ្មីឡើងវិញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ៨២ ចុះថ្ងៃទី២៥-១១-២០០២ របស់សាលាឧទ្ធរណ៍ ដោយអំណាចសាលដីការដ្ឋប្បវេណីលេខ២០៤ ចុះថ្ងៃទី២៦-០៨-០២ របស់តុលាការកំពូល ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ១៣៤ ចុះថ្ងៃទី០៨-១០-២០០១ របស់តុលាការខេត្តព្រៃវែងចោលជាអសារបង់ ។

៣-ប្រគល់ដីទំនាស់ទំហំ៣៥៤ម$^{២}$ ដែលមានព្រំប្រទល់ខាងជើងទល់នឹងដីឈ្មោះយឿន មុំ ខាងត្បូងទល់ផ្លូវ ខាងកើតទល់នឹងផ្លូវជាតិលេខ១១ និងខាងលិចទល់នឹងដីឈ្មោះផុន អូន ស្ថិតនៅភូមិពោធិចិន្តាំ ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ឱ្យទៅឈ្មោះឈថ កាន់កាប់ប្រើប្រាស់ និងគ្រប់គ្រងតទៅ ។

៤-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛ ចំណាយលើអាជ្ញាធរតុលាការ៥.០០០៛ និងបង្គាប់ឱ្យដើមចោទបង់ពន្ធសមាមាត្រ១%លើផ្ទៃដីទំនាស់។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៣១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះហផល ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៩៧(ច)ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះហផល ។

បានឃើញសារណាតបចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៤ របស់ឈ្មោះឈថ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ សាលាឧទ្ធរណ៍សម្រេចពុំមានលក្ខណៈត្រឹមត្រូវទេ សូមក្រុមប្រឹក្សាសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះហាផល នាពេលសវនាការថាៈ ដីទំនាស់ខ្លួនកាន់កាប់ពី១៩៧៩រហូតមកដោយបានស្ទូងស្រូវ ដាំឈូក កញ្ឆែតរាល់ឆ្នាំ មិនដែលខានទេ មានព្រំប្រទល់ត្រឹមត្រូវទៀតផង ឯឈថ នៅក្រោយឯណោះ មិនដែលប្រើប្រាស់ដីក្នុងទឹកនេះទេ ការកកើត ជាបុងទឹកនេះដោយសារខ្លួនជីកយកដីចាក់ផ្ទះ ហើយបុងទឹកខ្លួនគ្រប់គ្រងរហូតសព្វថ្ងៃ បានចិញ្ចឹមត្រីទៀត យកផលរាល់ឆ្នាំ ការកាន់កាប់ប្រធានភូមិបានដឹងឮទាំងអស់តែពេលសវនាការមិនចូលខ្លួន ឆ្លើយសោះពេលសុំផ្លូវដើរឱ្យដើរបែរជាទារយកដីទៀត កន្លងមកបានជាខ្លួនមិនបានធ្វើប័ណ្ណកម្មសិទ្ធិដោយយល់ថា ដីនេះជាបុងទឹករបស់ខ្លួនទៅហើយ បើរដ្ឋត្រូវការថ្ងៃណាទេ ឯចុងចម្លើយលួចធ្វើប័ណ្ណ បានដោយសារខ្លួនគាត់មេឃុំ និងឈថ ជាបងប្អូន និងគ្នា ។

បានស្តាប់ចម្លើយរបស់ឈ្មោះឈថ នាពេលសវនាការថាៈ ខ្លួនមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដីបុងទឹកនេះរដ្ឋអំណាចបែងចែកឱ្យខ្លួន តាមពិតដើមចោទ បានស្ទូងស្រូវ១ឆ្នាំគត់ លើដីចំណីថ្នល់ទៀត ឯខ្លួនបានដាំបន្លែ និងយកទឹកប្រើប្រាស់ មិនដែលសុំដើមចោទទេ ខ្លួនបានជីកយកដីធ្វើផ្លូវ ហើយបុងទឹកចិញ្ចឹមត្រី ឪពុកដើមចោទបានសុំខ្លួនជីកដីតែមួយជ្រុងតូចទេ ខ្លួនយល់ព្រមឱ្យដោយយល់ថា ជាបងប្អូនគ្នា ។ ចម្លើយរបស់ខ្លួនមានពីតុលាការថ្នាក់ក្រោមមកនោះមិនមែន ចម្លើយពិតប្រាកដរបស់ខ្លួនទេ សូមបដិសេធចោលទាំងអស់ គ្មាននរណាដឹងថាដីខ្លួនឯង ហើយបែរជាឆ្លើយថាជាដីរបស់គេទៅវិញនោះទេ ដោយសារដីបុងទឹកនេះ ឃុំអ្នកចែក ទើបឃុំបញ្ជាក់ ចុះបើហាផល ថា បានកាន់កាប់ដីបុងទឹករហូត ម្តេចមិនមានពាក្យសុំកាន់កាប់ដី ? ឯខ្លួនពេលដាក់ ពាក្យម្តេចដើមចោទមិនតវ៉ាទៅ ?

បានស្តាប់ចម្លើយរបស់ឈ្មោះហាផល បន្ថែមថាៈ បើចុងចម្លើយអះអាងថាខ្លួនមានបង្កាន់ដៃហើយមានប័ណ្ណទៀត ម្តេចចាំបាច់ប្តឹងខ្លួនធ្វើអី ?

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក............ ជាមេធាវីការពារឱ្យឈ្មោះឈថ បានលើកឡើងថាៈ ក្រោយពីបានស្តាប់ចៅក្រមអានរបាយការណ៍ និងចម្លើយរបស់គូភាគីពេលនេះ និងតាមសាលដីកាសាលាឧទ្ធរណ៍លើកទី១ និងទី២ រួមនិងសាលដីកាតុលាការកំពូលកាលលើកទី១ ផង ឃើញថា គូភាគីសុទ្ធតែបានលើកអំពីភស្តុតាង និងសំអាងរៀងៗខ្លួន ខ្លួនយល់ថា សំខាន់នោះ គឺភស្តុតាងដែលស្របទៅនឹងច្បាប់ចែង ទើបមានតម្លៃ ។ ចំពោះសាលដីការបស់តុលាការកំពូល ជំនុំជំរះលើកទី១នោះ គ្រាន់តែបានបង្វិលឱ្យសាលាឧទ្ធរណ៍បញ្ជាក់អំពីការយល់ឃើញឱ្យមានលក្ខណៈច្បាស់លាស់ និងអំពីបុព្វសិទ្ធិរបស់គូភាគីប៉ុណ្ណោះ តាមន័យនោះមានន័យថា ប្រគល់ដីឱ្យកូនក្តីខ្លួន បាត់ទៅហើយ តែវាគ្រាន់តែពុំមានន័យច្បាស់លាស់ យល់ន័យពុំទាន់អស់តែប៉ុណ្ណោះ ។ បើផ្អែកតាមការបំភ្លឺរបស់មេភូមិ និងមេឃុំកូនក្តីខ្លួនបានដាក់ពាក្យសុំកាន់កាប់ និងប្រើប្រាស់ដីធ្លីមានសាក្សី ដឹងឮទៀតផង តាមពិតបុងទឹកមានតាំងពីសង្គមចាស់

មកម្ល៉េះ ឈាងថុង ពុំបានឆ្លើយថា ដើមចោទ បានកាន់កាប់ដីបុងទឹកនេះពី១៩៧៩ ដល់២០០១ នោះទេ ហើយកន្លងមកតុលាការកំពូល ក៏ពុំទាន់បានទទួលស្គាល់ថា ដើមចោទជាម្ចាស់កម្មសិទ្ធិលើដីទំនាស់ទេ គ្រាន់តែបានទទួលស្គាល់ថាដើមចោទមានសិទ្ធិអាស្រ័យផលលើដីបុងទឹកនេះតែប៉ុណ្ណោះ ។ សាលដីការបស់សាលាឧទ្ធរណ៍ជំនុំជំរះលើកទី២ មានន័យគ្រប់គ្រាន់ហើយ គួរទទួលយកថាបានការ ។ ខ្លួនសំណូមពរដូចតទៅ :

សូមតម្កល់ការសម្រេចរបស់សាលាឧទ្ធរណ៍លើកទី២ទុកជាត្រឹមត្រូវ ហើយបើតុលាការកំពូលយល់ថា មិនទាន់ច្បាស់លាស់ សូមស្នើបអង្កេតបន្ថែមលើពាក្យសុំកាន់កាប់ដីរបស់ឪពុកដើមចោទ ម៉្យាងទៀតដីទំនាស់មិនទាន់មានលក្ខណៈច្បាស់លាស់លើបណ្ដោយ ទទឹង ជំរៅ និងពុំមានព្រំ ប្រទល់ច្បាស់លាស់ទេ រវាងបុងទឹក និងបុព្វសិទ្ធិអ្នកកាន់កាប់ដី ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយគូភាគី និងសេចក្ដីសន្និដានការពាររបស់មេធាវីចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថាបណ្ដឹងសាទុក្ខលេខ៣១៩ ចុះថ្ងៃទី២៤ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះហាផលធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានដោយ យោងតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងតាមមាត្រ២២៦ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌ ដែលមានអានុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចប្រគល់ដីបុងទឹកទំនាស់ឱ្យចុងចម្លើយ ដោយផ្អែកតាមចម្លើយបំភ្លឺរបស់សាក្សី និងរដ្ឋអំណាចមូលដ្ឋាន ព្រមទាំងបានដាក់ពាក្យសុំកាន់កាប់ នោះគឺជាការភ័ន្តច្រឡំ ពីព្រោះចុងចម្លើយបានឆ្លើយបញ្ជាក់ច្បាស់លាស់ពីរដងនៅមុខតុលាការគឺ នៅពេលផ្សះផ្សា ថ្ងៃទី២៨-០៦-២០០១ និងនៅពេលសវនាការនៅតុលាការខេត្តព្រៃវែងពីថ្ងៃទី០៨-១០-២០០១ ថា ដីបុងទឹកទំនាស់នេះ គឺដើមចោទបានប្រើប្រាស់តាំងពីឆ្នាំ១៩៧៩ រហូតមក ដូចជា ស្ទូង ស្រូវ ដាំឈូក យកទឹកពីបុងទឹកដាក់ស្រូវ និងជីកបុងទឹកនេះប្រាកដមែន ។ ដូច្នេះដើមចោទ មានសិទ្ធិលើដីបុងទឹកទំនាស់នេះ តាមមាត្រា៦២ និង៧៤ នៃច្បាប់ភូមិបាលចាស់ហើយ ។

-យល់ឃើញថា ពុំមានភស្តុតាងណាបញ្ជាក់ថា ចុងចម្លើយបានកាន់កាប់គ្រប់គ្រង ជីក បុងបន្ថែម និងអាស្រ័យផលលើដីបុងទឹកទំនាស់នេះទេ ។

-យល់ឃើញថា ពុំមានភស្តុតាងណាជាលាយលក្ខណ៍អក្សរបញ្ជាក់ថា ដើមចោទបានខ្ចីដី ទំនាស់នេះពីចុងចម្លើយទេ។ បើទោះជាមានការខ្ចីមែនក៏ចុងចម្លើយបានផ្ដោះសិទ្ធិទាមទារតាមមាត្រា២៥ នៃ

ក្រឹត្យច្បាប់លេខ៣៨ក្រច ចុះថ្ងៃទី២៨-១០-១៩៨៨ ហើយពីព្រោះថា ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ២០០១ ទើបចុងចម្លើយទាមទារដីបុងទឹកនេះវិញនោះ មានរយៈពេលជាង២០ឆ្នាំហើយ ។

-យល់ឃើញថា ការដែលចុងចម្លើយ និងមេធាវីចុងចម្លើយលើកឡើងនៅពេលសវនាការ នេះថា ដីបុងទឹកនេះ ដើមចោទបានកាន់កាប់តែនៅឆ្នាំ១៩៧៩ មួយឆ្នាំទេនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះនៅក្នុងកំណត់ហេតុផ្សះផ្សា និងនៅពេលសវនាការនៅតុលាការខេត្តព្រៃវែងថា ចាប់ពីឆ្នាំ១៩៧៩ មក ដើមចោទបានស្ទូង ដាំឈូក យកទឹកបុងដាក់ស្រូវ និងជីកបុង ប្រាកដមែន ដោយខ្លួនយល់ថា ឪពុកម្ដាយហផល ត្រូវជាពូមីង ទើបខ្លួនពុំមានថាអ្វីឱ្យគាត់ គាត់ធ្វើអ្វីក៏ធ្វើទៅ ។ ចម្លើយនេះមានន័យថា ដើមចោទមិនមែនកាន់កាប់បុងទឹកនោះ តែមួយឆ្នាំទេ ។

-យល់ឃើញថា ការដែលមេធាវីចុងចម្លើយសុំឱ្យតុលាការកំពូលចាត់របៀបស៊ើបអង្កេត បន្ថែមទៀតនោះ តុលាការកំពូលយល់ថា ពុំចាំបាច់ទេ ពីព្រោះលោកឈថ ខ្លួនឯង បានឆ្លើយបញ្ជាក់ច្បាស់លាស់នៅមុខតុលាកាហើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩៧(ច)ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ហើយ

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្ដីចំពោះមុខគូក្ដី

១-ទទួលបណ្ដឹងសាទុក្ខលេខ៣១៩ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់អ្នកស្រីហផល ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៩៧(ច) ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-ប្រគល់ដីបុងទឹកទំនាស់ទំហំ៣៥៤ម$^{២}$ ដែលមានព្រំប្រទល់ខាងជើងទល់ដីឈ្មោះយឿន ជុំ ខាងត្បូងទល់ផ្លូវ ខាងកើតទល់ផ្លូវជាតិលេខ១១ ខាងលិចទល់ដីឈ្មោះផុន អួន ស្ថិតនៅភូមិពោធិចិន្ដាំ ឃុំស្វាយអន្ទរ ស្រុកព្រៃវែង ខេត្តព្រៃវែង ឱ្យទៅឈ្មោះហផល កាន់កាប់ប្រើប្រាស់ និងគ្រប់គ្រងតទៅ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន១៥.០០០៛ ដែលអ្នកស្រីហផល បានបង់គឺៈ

-ពន្ធចុះបញ្ជីក្ដី នឹងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវឱ្យលោកឈថ សងប្រាក់១៩.០០០៛ នេះទៅដើមចោទវិញ ។

បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ១% លើតម្លៃដីបុងទឹកទំនាស់ ។

៥-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០១ខែសីហាឆ្នាំ២០០៥